# ស្វែងយល់ពីទ្រឹស្តីអភិវឌ្ឍន៍ពឹងផ្អែក (Dependency)

In what ways and to what extent does dependency lead to underdevelopment?

*ដោយ៖ បណ្ឌិត **តូច សុធារី** និង លោក **សាន ចេង***
*មន្ត្រីនាយកដ្ឋានវិទ្យាសាស្ត្រសេដ្ឋកិច្ច និងទេសចរណ៍*
*នៃវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

## ១.សេចក្តីផ្តើម

ប្រទេសក្នុងប្រព័ន្ធសេដ្ឋកិច្ចសកលលោក ពឹងផ្អែកលើគ្នាទៅវិញទៅមកដើម្បីអភិវឌ្ឍនិង រីកចម្រើនទៅមុខៗ មានសំណួរជុំវិញការអភិវឌ្ឍ របស់ប្រទេសតតិយលោក ដែលក្នុងនោះមាន ក្រុមប្រទេសនៅទ្វីបអាម៉េរិកឡាទីន និង អាហ្វ្រិក ជាអាទិ៍ត្រូវបានលើកឡើង ជាពិសេសនៅក្រោយ សង្គ្រាមលោកលើកទីពីរ។ គោលនយោបាយ ជំនួសដោយការនាំចូល ដែលត្រូវបានផ្តួចផ្តើម ឡើងនៅក្នុងប្រទេសជាច្រើននៅទ្វីបអាហ្វ្រិកក្នុង អំឡុងពេលអាណានិគម នាំឱ្យមានការពឹងផ្អែក កាន់តែច្រើនលើការនាំចូលធនធាន គ្រឿងចក្រ ទំនិញឧស្សាហកម្ម និងបច្ចេកវិទ្យាទំនើប ព្រមទាំង ធនធានមនុស្សសំខាន់ដែរ (Chukwuemeka, Anazodo, & Nzewi, 2011)។ តើការពឹងផ្អែករបស់ ប្រទេសរណបសេដ្ឋកិច្ចលើមជ្ឈមណ្ឌលស្នូលនៃ អំណាចសេដ្ឋកិច្ចរបស់បស្ចិមលោកនាំឱ្យមាន ការអភិវឌ្ឍមិនបានឬយ៉ាងណា? ទ្រឹស្តីពឹង ផ្អែក (Dependency Theory) បានកើតឡើង ដំបូងនៅដើមទសវត្សរ៍ឆ្នាំ១៩៦០ ជាការឆ្លើយ តបទៅនឹងការបរាជ័យនៃកម្មវិធីអភិវឌ្ឍរបស់ អង្គការសហប្រជាជាតិមួយដែលមានឈ្មោះថា គណៈកម្មការសេដ្ឋកិច្ច សម្រាប់ការអភិវឌ្ឍ អាម៉េរិកឡាទីន (Economic Commission for Latin America)(Hite, 2000; Isbister, 1991; P. Preston, 2011; So, 1990; Webster, 1984)។ P. W. Preston (1996) ពន្យល់បង្ហាញថា វាត្រូវ បានបង្កើតឡើងដោយបទពិសោធន៍ប្រវត្តិសាស្ត្រពិសេស នៃទ្វីបអាម៉េរិកឡាទីនក្នុងទសវត្សរ៍ឆ្នាំ ១៩៤០ និង ១៩៥០ នៅពេលដែលគំរូពាណិជ្ជកម្ម និង សេដ្ឋកិច្ចបង្កើតឡើងជាយូរមក ហើយនោះ រំខានដោយព្រឹត្តការណ៍សង្គ្រាម លោកលើកទីពីរ និង ការកំណត់នូវវិធានការ និង គោលនយោបាយជាតិឧស្សាហកម្ម ជំនួស ដោយការនាំចូល (Import-Substitution Industrialisation)។ អ្នករៀបចំគោលនយោបាយ នេះរិះគន់និងមិនគាំទ្រលើទ្រឹស្តីទំនើបភាវូបនីយកម្ម (Modernization Theory) ដែលកើត ចេញមកពីប្រព័ន្ធសេដ្ឋកិច្ចមូលធនអឺរ៉ុបទេ។

គោលនយោបាយនេះ ផ្តល់ហេតុផលនិងអះអាងថា ការអភិវឌ្ឍតាមលំនាំទ្រឹស្តីទំនើបភាវូបនីយកម្មរារាំងវឌ្ឍនភាព ហើយព្រមទាំងបានទាញយកផលប្រយោជន៍ ពីប្រទេសមិនមានការអភិវឌ្ឍខ្លាំង (The Global South) ទៅវិញទេ។ លើសពីនេះទៀត វាថែមទាំងធ្វើឱ្យយើងយល់ច្បាស់អំពីទំនាក់ទំនងសង្គម សេដ្ឋកិច្ច និងនយោបាយនៃប្រទេសកំពុងអភិវឌ្ឍឬតតិយលោកដែរ ជាពិសេសបណ្តាប្រទេសនៅអាម៉េរិកឡាទីននិងទ្វីបអាហ្វ្រិក ជាមួយនឹងបណ្តាប្រទេសមូលធននិយមសំខាន់ៗនៅអឺរ៉ុបខាងលិច និងអាម៉េរិកខាងជើង (Desai & Potter, 2002)។ ក្នុងទិដ្ឋភាពនេះ វាបានបង្ហាញយ៉ាងច្បាស់ថាក្រុមប្រទេសមូលធននិយម ជាពិសេសនៅអឺរ៉ុបខាងលិច និងអាម៉េរិកខាងជើង ពឹងផ្អែកលើក្រុមប្រទេសកំពុងអភិវឌ្ឍឬតតិយលោក ដើម្បីរីកចម្រើនទៅវិញ។ តាមទស្សនៈនៃទ្រឹស្តីពឹងផ្អែក (Dependency Theory) បណ្តាប្រទេសតតិយលោកមានសន្ទុះអភិវឌ្ឍតិចតួចនៅក្នុងប្រព័ន្ធសេដ្ឋកិច្ចមូលធននិយម ដោយសារតែការកេងប្រវ័ញ្ចមិនអាចកែប្រែរបស់ប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន តាមរយៈការដោះដូរពាណិជ្ជកម្មមិនស្មើគ្នា ការវិនិយោគ នៃក្រុមហ៊ុនសាជីវកម្មពហុជាតិបរទេសច្រើន (Multinational Corporations) និងការពឹងផ្អែកលើប្រព័ន្ធសេដ្ឋកិច្ចមូលធន។ អត្ថបទនេះពន្យល់និងបង្ហាញពីមធ្យោបាយនានា ដែលធ្វើឱ្យការអភិវឌ្ឍលំនាំពឹងផ្អែក (Dependency) ធ្វើឱ្យប្រទេសក្រីក្រ មានសន្ទុះអភិវឌ្ឍតិចតួចទៅវិញ ហើយអត្ថបទនេះនឹងវិភាគនូវកត្តាផ្សេងៗ ដែលរួមចំណែកធ្វើឱ្យមានការអភិវឌ្ឍតិច និង យឺត (Underdevelopment) ចំពោះប្រទេសតតិយ លោកផងដែរ។

## ២.ទំនាក់ទំនងនៃសេដ្ឋកិច្ចពឹងផ្អែកទៅនឹងការអភិវឌ្ឍតិចតួច

ហេតុផលទីមួយបង្ហាញថា ការពឹងផ្អែកលើពាណិជ្ជកម្មអន្តរជាតិ និង ការវិនិយោគពីបរទេស អាចនាំប្រទេសតតិយលោកទៅរកការអភិវឌ្ឍតិចតួច (Underdevelopment)។ ទីផ្សារនិងពាណិជ្ជកម្មរបស់ប្រទេសក្រីក្រ ជាធម្មតាពឹងផ្អែកខ្លាំង លើប្រព័ន្ធទីផ្សាររបស់ប្រទេសជឿនលឿន (Developed Countries) (Hite, 2000)។ ការដោះដូរមិនស្មើគ្នានៅក្នុងទីផ្សារសកល អាចឱ្យយើងមើលឃើញយ៉ាងច្បាស់ថា ជាការកេងប្រវ័ញ្ចមិនប្រែប្រួល និង មិនអាចកែប្រែបាន។ Isbister (1991) អះអាងថា បណ្តាប្រទេសក្រីក្រ និង ទន់ខ្សោយ ជាធម្មតាទទួលបានផលចំណេញសេដ្ឋកិច្ច តិចជាងបណ្តាប្រទេសធំដែលមានសេដ្ឋកិច្ចជឿនលឿន ចំពោះការដោះដូរទំនិញនៅក្នុងទីផ្សារពាណិជ្ជកម្មអន្តរជាតិ បើទោះបីជាពួកគេបានខាតបង់ផលចំណេញច្រើនហើយក៏ដោយក្តី។ តម្លៃផលិតផលកសិកម្មដែលនាំចេញទៅក្រៅប្រទេស ដោយប្រទេសក្រីក្រនៅមានកម្រិតទាប

បើធៀបនឹងតម្លៃនៃការនាំចូលផលិតផល និង ទំនិញនៃប្រទេសឧស្សាហកម្ម។ ប្រទេសជឿនលឿនមានអំណាចខ្លាំង និង ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចចិត្តថា តើនៅពេលណា និង របៀបណាចំពោះការដោះដូរពាណិជ្ជកម្មនៅក្នុងទីផ្សារសកល ហើយពួកគេជាអ្នកកំណត់តម្លៃទៅតាមលំហូរប្រព័ន្ធសេដ្ឋកិច្ចរបស់ពួកគេ។ Matunhu (2011) ពន្យល់ថា វត្ថុធាតុដើមរបស់ប្រទេសក្រីក្រដែលមានគឺប្រើប្រាស់សម្រាប់ជាការផ្គត់ផ្គង់ដល់ច្រវាក់ផលិតកម្មរបស់ប្រទេសអ្នកមាន។ ប្រាក់ឈ្នួលពលកម្មដែលទទួលបានសម្រាប់កម្មករនៅក្នុងប្រទេសក្រីក្រគឺមានចំនួនតិចជាងកម្រៃដែលកម្មករនៅប្រទេសអ្នកមានទទួលបានច្រើន។ តាមរយៈការដោះដូរពាណិជ្ជកម្មនេះ ប្រទេសអ្នកមានទទួលបានអត្ថប្រយោជន៍លើការផ្ទេរតម្លៃ (Value Transfer) ច្រើនលើសលប់ (Hite, 2000)។ ប្រទេសក្រីក្រដែលស្ថិតនៅក្រោមឥទ្ធិពលប្រព័ន្ធសេដ្ឋកិច្ចមូលធននេះត្រូវបានគេមើលឃើញថាជាជនរងគ្រោះ និង បាត់បង់ធនធាននៅក្នុង ក្របខណ្ឌនិងសកម្មភាពដោះដូរពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគបរទេស។ ទិដ្ឋភាពនេះហាក់ដូចជាបានស្តែងចេញនូវរូបភាពអាណានិគមនិយមបែបថ្មីដែលអ្នកសាមញ្ញធម្មសឹងតែមើលមិនឃើញនិងស្វែងយល់បាន។ នៅក្នុងដំណើរការនេះ ប្រទេសអ្នកមានអាចបង្កើនមូលធនកាន់តែច្រើន ពីប្រទេសក្រីក្រទាំងនោះដែលមានការអភិវឌ្ឍតិចតួច។ ឧទាហរណ៍ នៅក្នុងកំឡុង សម័យសង្គ្រាមត្រជាក់ Bodenheimer (1971) អះអាងថា ការវិនិយោគបរទេសជាពិសេសពីសហរដ្ឋអាម៉េរិក និងពីបណ្តាប្រទេសឧស្សាហកម្មជឿនលឿន បណ្តាលឱ្យមានលំហូរ មូលធនចេញយ៉ាងច្រើនពីប្រទេសដែលមិនទាន់មានការអភិវឌ្ឍ ជាពិសេសពីបណ្តាប្រទេសនៅទ្វីបអាម៉េរិកឡាទីន និង អាហ្វ្រិក។ ដូចអ្វីដែលបានលើកឡើងខាងដើម វាបានបង្ហាញឱ្យឃើញកាន់តែច្បាស់ថា ប្រទេសក្រីក្រត្រូវបានកេងប្រវ័ញ្ចយ៉ាងខ្លាំង ដោយប្រទេសអ្នកមាន ហើយកាន់តែធ្វើឱ្យពួកគេក្រទៅៗ។

ហេតុផលទីពីរស្រដៀងនឹងការពិភាក្សាក្នុងហេតុផលទីមួយដែរ។ ការជ្រៀតចូលនៃក្រុមហ៊ុនសាជីវកម្មពហុជាតិរបស់ប្រទេសឧស្សាហកម្មជឿនលឿន ក៏អាចជាកត្តាធ្វើឱ្យមានការអភិវឌ្ឍតិចតួចនៅក្នុងបណ្តាប្រទេសក្រីក្រដែលទទួលយកក្រុមហ៊ុនទាំងនោះដែរក្នុងក្របខណ្ឌពាណិជ្ជកម្មអន្តរជាតិដែរ។ ប្រទេសអ្នកមានកេងប្រវ័ញ្ចប្រជាជនក្រីក្រដោយយកអតិរេកសេដ្ឋកិច្ចពីប្រទេសក្រីក្រដែលគេស្គាល់ថាជាទម្រង់នៃការធ្វើអាណានិគមបែបថ្មី។ ប្រាក់ចំណេញ និងមូលធនសន្សំដែលទទួលបានដោយក្រុមហ៊ុនសាជីវកម្មពហុជាតិក្នុងប្រទេសក្រីក្រត្រូវបានបញ្ជូនទៅប្រទេសអ្នកមានតាមរយៈប្រតិបត្តិការហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

Isbister (1991) បង្ហាញថា ក្រុមហ៊ុនសាជីវកម្មពហុជាតិបរទេសមានដើមទុនតិចតួចដើម្បីវិនិយោគក្នុងប្រទេសក្រីក្រ ប៉ុន្តែពួកគេខ្ចីពីអ្នកសន្សំក្នុងស្រុក ហើយប្រាក់ចំណេញដែលពួកគេរកបានគឺតែងតែបញ្ជូនទៅកាន់ប្រទេសដើមរបស់ពួកគេៗ លើសពីនេះក្រុមហ៊ុនសាជីវកម្មពហុជាតិបរទេសនាំយកមកជាមួយនូវបច្ចេកវិទ្យាជឿនលឿនខ្ពស់ខ្លាំងសម្រាប់បម្រើក្នុងដំណើរការប្រវាក់ផលិតកម្មទំនិញដែលមិនស៊ីគ្នានឹងកម្លាំងពលកម្មច្រើនលើសលប់នៃប្រទេសក្រីក្រៗ នេះជាហេតុធ្វើឱ្យមានភាពអត់ការងារធ្វើមួយចំនួនធំនៅក្នុងតំបន់នៃប្រទេសក្រីក្រទាំងនោះ (Stein, 1979)។ លើសពីនេះទៅទៀត ក្រុមហ៊ុនសាជីវកម្មពហុជាតិទាំងនោះដែលបានវិនិយោគនៅក្នុងតំបន់ប្រទេសក្រីក្រទាំងនោះ តែងតែប្រើប្រាស់អំណាចផ្តាច់មុខ (Monopoly Power) ក្នុងការលក់និងការប្រើប្រាស់ផលិតផល ដែលវាបានជះឥទ្ធិពលអវិជ្ជមានដល់ការបែងចែកធនធាននៅក្នុងប្រទេសក្រីក្រដែលមានសេដ្ឋកិច្ចពឹងផ្អែកៗ លទ្ធភាពនៃការបង្កើតការវិនិយោគថ្មីគឺពឹងផ្អែកលើរូបិយប័ណ្ណបរទេសដើម្បីទិញគ្រឿងម៉ាស៊ីន និងសម្ភារៈមួយចំនួនដែលជារបស់មិនមែនផលិតក្នុងស្រុក (Santos, 1970) ដូចនេះតម្លៃគឺខ្ពស់ដែលកំណត់ដោយទំនាក់ទំនងតម្រូវការនិងការផ្គត់ផ្គង់របស់ប្រទេសឧស្សាហកម្មជឿនលឿនទាំងនោះ។ ប្រទេសដែលមានកម្លាំងសេដ្ឋកិច្ចទាបឬប្រទេសក្រីក្រនិយាយជារួម គឺមិនអាចធ្វើការប្រកួតប្រជែងដោយស្មើភាពក្នុង ទីផ្សារសេរីសកលបានទេ ហើយពួកគេគ្រាន់តែអាចជ្រើសរើសគំរូឧស្សាហកម្មដែលអាស្រ័យលើគោលនយោបាយពន្ធបង្កើតឡើងដោយអនុត្តរភាពនៃប្រទេសមានសេដ្ឋកិច្ច ជឿនលឿនប៉ុណ្ណោះ។ ឧទាហរណ៍ ធនាគារពិភពលោក (The World Bank) និង មូលនិធិរូបិយវត្ថុអន្តរជាតិ (IMF) ដែលបានផ្តួចផ្តើមបង្កើតដំបូងដោយសហរដ្ឋអាម៉េរិក ឈរនៅពីក្រោយ និងគាំទ្រក្រុមហ៊ុនសាជីវកម្មពហុជាតិបរទេសទាំងនោះ ហើយបង្កើតគោលនយោបាយសេដ្ឋកិច្ចនិងវិធានការនានាដែលបម្រើដល់ផលប្រយោជន៍ក្រុមហ៊ុនបរទេសទាំងនោះ និងអាចរកប្រាក់ចំណេញបានពីប្រទេសក្រីក្រទាំងនោះ (Isbister, 1991)។ ជាទូទៅ នៅក្នុងប្រព័ន្ធសេដ្ឋកិច្ចសកល ប្រទេសទន់ខ្សោយជាធម្មតារណបនឹងប្រទេសខ្លាំងដែលមានអំណាចជាងនៅក្នុងទីផ្សារអន្តរជាតិ។ ប្រទេសខ្លាំងនិងមានអំណាចទាំងនោះគឺជាអ្នកកំណត់តម្លៃនិងផលចំណេញដែលទទួលបាននៅក្នុងទីផ្សារ។ តួអង្គប្រទេសដែលមានឥទ្ធិពលច្រើនជាង តែងតែប្រើអំណាចរបស់ពួកគេដើម្បីត្រួតត្រា ហើយកំណត់ក្នុងការបែងចែកប្រាក់ចំណេញក្នុងដំណើរការដោះដូរពាណិជ្ជកម្ម (Hite, 2000)។ ក្នុងកាលៈទេសៈមួយចំនួននៃការធ្លាក់ចុះដំណើរការពាណិជ្ជកម្ម វាអាចបង្ខំ

ឱ្យប្រទេសក្រីក្រទាំងនោះខ្ចីឥណទានបរទេសកាន់តែច្រើនពីទីភ្នាក់ងារជំនួយអន្តរជាតិ ហើយពួកគេអាចជាប់បំណុលយ៉ាងធ្ងន់ធ្ងរ (Saul, 2006)។

សម្រាប់ហេតុផលចុងក្រោយចំពោះការពន្យល់នេះ គឺការពឹងផ្អែកផ្នែកសេដ្ឋកិច្ចក៏អាចរួមចំណែកយ៉ាងសំខាន់ធ្វើឱ្យមានការអភិវឌ្ឍមិនប្រក្រតីនៅក្នុងប្រទេសក្រីក្រ។ ការបង្ខូចទ្រង់ទ្រាយប្រព័ន្ធសេដ្ឋកិច្ច និងឥទ្ធិពលនៃ ទីផ្សារពាណិជ្ជកម្មអន្តរជាតិអាចបង្ខំឱ្យប្រទេសក្រីក្រទទួលយករចនាសម្ព័ន្ធសេដ្ឋកិច្ចដែលជារឿយៗមិនស៊ីប្រវាក់គ្នាជាមួយនឹងបែបផែននៃការអភិវឌ្ឍសេដ្ឋកិច្ចតាមតំបន់ប្រទេសក្រីក្រទាំងនោះ។ So (1990) បញ្ជាក់ថា តាមទស្សនៈនេះ សេដ្ឋកិច្ចរបស់ប្រទេសក្រីក្រទាំងនោះជាធម្មតាទទួលគំនៀបនិងឥទ្ធិពល ហើយកេងប្រវ័ញ្ចដោយអំណាចប្រទេសអ្នកមាន។ ហេតុដូចនេះហើយបានជាប្រទេសកំពុងអភិវឌ្ឍមួយចំនួនកាន់តែក្រ និង អភិវឌ្ឍតិចតួចដោយសារការកេងប្រវ័ញ្ចពីប្រទេសមូលធននិយម។ Isbister (1991) បន្ថែមថាការរីកចម្រើននៃប្រទេសអ្នកមាននាពេលបច្ចុប្បន្នគឺជាការឆ្លុះបញ្ចាំងពីភាពក្រីក្រនៃប្រទេសក្រីក្រដែលមានទំនាក់ទំនងនយោបាយ សេដ្ឋកិច្ច និងពាណិជ្ជកម្មជាមួយខ្លួន។ Isbister (1991) អះអាងថា ការអភិវឌ្ឍតិចតួចមិនមែនគ្រាន់តែជាការបរាជ័យក្នុងការអភិវឌ្ឍប៉ុណ្ណោះទេ ប៉ុន្តែវាគឺជាដំណើរការដែលធ្វើឱ្យមានភាពក្រីក្រមិនចេះរីងស្ងួត ។ ប្រទេសមហាអំណាចសេដ្ឋកិច្ចស្នូលប្រើប្រាស់មធ្យោបាយផ្សេងៗដើម្បីបង្ខូចទម្រង់ និងបែបផែននៃការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេសទន់ខ្សោយ។ ពួកគេគ្រប់គ្រងរចនាសម្ព័ន្ធសេដ្ឋកិច្ចដើម្បីរារាំងវឌ្ឍនភាពនៅក្នុងប្រទេសទន់ខ្សោយទាំងនោះ។ ឧទាហរណ៍ ការបែងចែកពលកម្មសកលនានាបង្កើតឱ្យមានឧបសគ្គដល់ការអភិវឌ្ឍសេដ្ឋកិច្ចក្នុងប្រទេសក្រីក្រ។ កម្មករនៅក្នុងប្រទេសក្រីក្រអាចទទួលបានប្រាក់ឈ្នួលទាបខ្លាំងបើប្រៀបធៀបនឹងប្រាក់ឈ្នួល និងអត្ថប្រយោជន៍ដែលទទួលបានដោយកម្មករនៅក្នុងប្រទេសអ្នកមាន។ ជាងនេះទៅទៀត បណ្ដាប្រទេសមូលធននិយម មើលឃើញនិងចាត់ទុកថា ប្រទេសក្រីក្រទាំងនោះជាអ្នកផ្គត់ផ្គង់វត្ថុធាតុដើមដល់ពួកគេ ដើម្បីជំរុញការរីកចម្រើននៃឧស្សាហូបនីយកម្មពួកគេ។ ដូច្នេះហើយ ពួកគេតម្រង់ទិសបណ្ដាប្រទេសក្រីក្រទាំងនោះឱ្យមានលទ្ធភាពក្នុងការផលិតវត្ថុធាតុដើមដែលមិនមានលក្ខណៈខុសគ្នា ដើម្បីបំពេញតម្រូវការពួកគេ។ ស្ថានភាពមិនប្រែប្រួលនិងដដែលៗនេះអាចធ្វើឱ្យប្រទេសក្រីក្រទាំងនោះមិនមានការប្រកួតប្រជែងក្នុងប្រព័ន្ធសេដ្ឋកិច្ចសកល។ Ray (1973) បញ្ជាក់ថា ការអភិវឌ្ឍសេដ្ឋកិច្ចរបស់អាម៉េរិកឡាទីនក្នុងប្រវត្តិសាស្ត្រក្រោយសង្គ្រាមលោកលើកទីពីរត្រូវបានបន្ទុចបង្អាក់និងកំណត់ដោយតម្រូវ

ការរបស់ប្រទេសមហាអំណាចសេដ្ឋកិច្ចស្ទួលនៅក្នុងទីផ្សារពិភពលោក។ តម្លៃទំនិញប្រើប្រាស់របស់ប្រទេសក្រីក្រធ្លាក់ចុះដោយសារផលិតកម្មឧស្សាហកម្មផលិតដោយប្រទេសអ្នកមាន។ Hite (2000) ពន្យល់ថា នេះអាចបង្កការលំបាកដល់ប្រទេសក្រីក្រក្នុងការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការគៀបសង្កត់សេដ្ឋកិច្ចជាប្រព័ន្ធបែបនេះអាចធ្វើឱ្យប្រជាជននៃប្រទេសទន់ខ្សោយកាន់តែលំបាកនិងមិនអាចរីកចម្រើនទៅមុខឱ្យដូចប្រជាជននៅក្នុងប្រទេសអ្នកមាន។

## ៣.ការរិះគន់លើទ្រឹស្តីអភិវឌ្ឍន៍ពឹងផ្អែក

ទោះជាយ៉ាងណាក៏ដោយ អ្នករិះគន់ទ្រឹស្តីពឹងផ្អែក (Dependency Theory) មួយចំនួនបានអះអាងថា ទំនាក់ទំនងដ៏រឹងមាំនៃប្រទេសក្រីក្រ (ប្រទេសរណបសេដ្ឋកិច្ច) ជាមួយនឹងប្រទេសមហាអំណាចសេដ្ឋកិច្ចស្ទួលផ្តល់ផលវិជ្ជមានច្រើនជាងភាពអវិជ្ជមានដែលបានលើកឡើង ជាពិសេសនិយាយដោយចំពោះ ក្នុងទំនាក់ទំនងពាណិជ្ជកម្មក៏ដូចជាការដោះដូរការវិនិយោគរបស់ក្រុមហ៊ុនសាជីវកម្មពហុជាតិ និងការពឹងផ្អែកនានាក្នុងសកម្មភាពសេដ្ឋកិច្ច។ ឧទាហរណ៍ ក្រុមហ៊ុនសាជីវកម្មពហុជាតិបាននាំមកនូវអត្ថប្រយោជន៍យ៉ាងច្រើនដល់ប្រទេសក្រីក្រ តាមរយៈការវិនិយោគ ដូចជាការផ្តល់ដើមទុន ការងារ និងប្រាក់ចំណូលផងដែរ (Chukwuemeka et al., 2011)។ ជាងនេះទៅទៀត ការលេចចេញនូវទម្រង់ការអភិវឌ្ឍតិចតួច (Underdevelopment) ក៏ដោយសារតែរចនាសម្ព័ន្ធសង្គមទន់ខ្សោយរបស់ប្រទេសក្រីក្រខ្លួនឯង (Webster, 1984)។ ក្រុមអភិជនក្នុងប្រទេសក្រីក្រដែលកាន់កាប់ជំនួញ និង អំណាចសេដ្ឋកិច្ចមានទំនាក់ទំនង និងពឹងផ្អែកលើអ្នកវិនិយោគនៃប្រទេសអ្នកមានក្នុងប្រទេសរបស់ខ្លួនដើម្បីគ្រប់គ្រងការអភិវឌ្ឍកសិកម្ម និងឧស្សាហកម្មនានា ហើយផ្តើមកេងប្រវ័ញ្ចលើវណ្ណៈកសិករតាមរយៈសកម្មភាពពាណិជ្ជកម្ម និងសេដ្ឋកិច្ចក្នុងស្រុក។

អ្នករិះគន់ទ្រឹស្តីខ្លះទៀត ប្រកែកថាតម្លៃអតិរេកដែលបានផ្ទេរទៅប្រទេសមូលធននិយមតាមរយៈប្រតិបត្តិការហិរញ្ញវត្ថុក្រុមហ៊ុនសាជីវកម្មពហុជាតិគឺគ្រាន់តែជាចំនួនជាក់ស្តែងនៃរូបិយវត្ថុប៉ុណ្ណោះ។ តម្លៃអតិរេកចាំបាច់ត្រូវបង្ហាញពីរបៀបដែលគេថាវាត្រូវបានកេងប្រវ័ញ្ច ហើយតាមពិតប្រទេសក្រីក្រទាំងនោះទេដែលពឹងផ្អែកយ៉ាងខ្លាំងលើប្រព័ន្ធផលិតកម្មមូលធននិយមទាំងស្រុង ដើម្បីជំរុញកំណើនសេដ្ឋកិច្ច (Webster, 1984)។ ការចោទប្រកាន់លើការកេងប្រវ័ញ្ចលើអតិរេកតម្លៃរបស់ក្រុមហ៊ុនសាជីវកម្មពហុជាតិគឺមិនសមហេតុសមផលឡើយ។ ជាការពិតណាស់ ដំណាក់កាលដំបូង ប្រទេសក្រីក្រត្រូវពឹងលើប្រទេសអ្នកមានដើម្បីអភិវឌ្ឍ ព្រោះពួកគេមិនមានលទ្ធភាពគ្រប់គ្រាន់ដោយខ្លួនឯងដើម្បីដើរទៅមុខឡើយបានឡើយ (Grosfoguel, 2000)។ ក្នុងប្រវត្តិសាស្ត្រ

អភិវឌ្ឍ ជាពិសេសនៅក្រោយសង្គ្រាមលោកលើកទីពីរ មានប្រទេសក្រីក្រជាច្រើនដែលបានអភិវឌ្ឍខ្លួន និងអាចឈានដល់ដំណាក់កាលនៃឧស្សាហូបនីយកម្ម ហើយក្រោយមកបានក្លាយជាប្រទេសដែលមានសេដ្ឋកិច្ចជឿនលឿន។ ជាឧទាហរណ៍ជាក់ស្តែង បណ្តាប្រទេសឧស្សាហកម្មថ្មី (Newly-Industrialized Countries ) ដែលរួមមានកូរ៉េខាងត្បូង សិង្ហបុរី ហុងកុង (ប្រទេសចិនសព្វថ្ងៃ) និង ដែនកោះតៃវ៉ាន់នៃប្រទេសចិន បានធ្វើសមាហរណកម្មទៅក្នុងទីផ្សារអន្តរជាតិ និងប្រព័ន្ធមូលធននិយមពិភពលោក ទទួលបានការអភិវឌ្ឍន៍ ហើយប្រែក្លាយទៅជាប្រទេសឧស្សាហកម្ម និង មានសេដ្ឋកិច្ចជឿនលឿនបំផុតនៅក្នុងតំបន់អាស៊ី ដូចបណ្តាប្រទេសនៅអឺរ៉ុបខាងលិច និងអាម៉េរិកខាងជើងដែរមួយចំនួនដែរ (Saul, 2006)។

បន្ថែមពីនេះទៀត Cardoso និង Faletto (1979) លើកឡើងថា ពេលដែលការវិនិយោគបរទេសចាប់ផ្តើមនៅក្នុងប្រទេសដែលមានសេដ្ឋកិច្ចពឹងផ្អែក ទីផ្សារក្នុងស្រុកមានមុខងារ និងមានដំណើរការ ហើយក្រុមអភិជនដែលនៅស្រទាប់លើរចនាសម្ព័ន្ធសង្គមទទួលបានអត្ថប្រយោជន៍ច្រើនបំផុត ក្នុងការបែងចែកផលចំណេញព្រោះពួកគេមានធនធាននិងអំណាចគ្រប់គ្រាន់ដើម្បីចាប់ផ្តើមវិនិយោគនិងដណ្តើមទីផ្សារមុនគេលើវិស័យនានាដែលមានសក្តានុពល។ Matunhu (2011) បកស្រាយថា ខណៈពេលដែលប្រទេសអ្នកមានកំពុងកេងប្រវ័ញ្ចនិងទាញយកធនធានរបស់ប្រទេសរណបសេដ្ឋកិច្ចខ្លួនក្នុងសកម្មភាពសេដ្ឋកិច្ចក្នុងចរន្តទីផ្សារអន្តរជាតិ និងការវិនិយោគ ពេលនោះអ្នកមានឥទ្ធិពល (ក្រុមអភិជនដែលមានអំណាច) នៅក្នុងប្រទេសក្រីក្រ ក៏កំពុងកេងប្រវ័ញ្ចប្រជាជនក្រីក្រនិងទន់ខ្សោយតាមរយៈសកម្មភាពពាណិជ្ជកម្មក្នុងស្រុកដែរ។ ទិដ្ឋភាពនេះ គឺបានបង្ហាញពីរចនាសម្ព័ន្ធកេងប្រវ័ញ្ចចេញពីអំណាចខាងក្រៅនិងខាងក្នុងផង ចំពោះប្រទេស និងប្រជាជនក្រីក្រដែលមិនអាចកែប្រែបាន។ ទោះបីជាក្រុមហ៊ុនសាជីវកម្មពហុជាតិគ្រប់គ្រងសេដ្ឋកិច្ចពិភពលោកក៏ដោយ អន្តរាគមន៍កាន់តែខ្លាំងរបស់អាជ្ញាធរ និងរដ្ឋាភិបាលប្រទេសក្រីក្រអាចទប់ស្កាត់ការកេងប្រវ័ញ្ចទាំងនោះបាន ហើយតម្លៃអតិរេកអាចត្រូវបានប្រើប្រាស់ជាប្រយោជន៍សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិបាន។ អ្នករិះគន់ទាំងនោះពន្យល់បន្ថែមថា មូលហេតុចំបងគឺ អាជ្ញាធរ និងរដ្ឋាភិបាលទាំងនោះពុករលួយ និងអសមត្ថភាពក្នុងការរៀបចំវិធានការទប់ស្កាត់ ជាពិសេសគឺការអនុវត្តន៍គោលនយោបាយផ្ទាល់តែម្តង (Willis, 2011)។ លើសពីនេះទៅទៀត ប្រទេសក្រីក្រទាំងនោះមិនមានបច្ចេកវិទ្យា មធ្យោបាយ និងធនធានគ្រប់គ្រាន់ ដូច្នេះហើយឧស្សាហូបនីយកម្មមានភាពយឺតយ៉ាវ និងទន់ខ្សោយដែលតម្រូវឱ្យពឹងផ្អែកលើ

បច្ចេកទេសនៃប្រទេសជឿនលឿនទាំងស្រុង។ ឧទាហរណ៍ សង្គមអាម៉េរិកឡាទីនត្រូវបានគេជឿថាមានលក្ខណៈបុរាណ និង មិនងាយកែប្រែដែលអាចឈានទៅសង្គមទំនើបបែបអឺរ៉ុបខាងលិច និងអាម៉េរិកខាងជើងឡើយ (Grosfoguel, 2000)។ ទិដ្ឋភាពបុរាណនៃសង្គមនេះ ធ្វើឱ្យយើងកាន់តែនឹកដល់សង្គមអាស៊ីនិងអាហ្វ្រិកមួយចំនួនទៀត ដែលភាគច្រើនលើសលប់មិនងាយឈានទៅរកទំនើបកម្មលឿនបានឡើយ ទោះជានៅក្នុងសតវត្សទី២១នេះ។

### ៤. គំនិតគាំទ្រទ្រឹស្តីអភិវឌ្ឍពឹងផ្អែក

ទោះជាយ៉ាងណាក៏ដោយ អ្នកទ្រឹស្តីពឹងផ្អែក (Dependency Theorist) មួយចំនួននៅតែជំទាស់ថា លើសពីការកេងប្រវ័ញ្ចធនធានចំពោះប្រទេសក្រីក្រ ការវិនិយោគបរទេសអាចបង្កើតភាពអត់ការងារធ្វើដោយសារតែការប្រើប្រាស់បច្ចេកវិទ្យាខ្ពស់នៅក្នុងរោងចក្រក្នុងប្រទេសក្រីក្រទាំងនោះ (Chukwuemeka et al., 2011)។ ជាងនេះទៅទៀត ការវិនិយោគរបស់ក្រុមហ៊ុនសាជីវកម្មពហុជាតិនៅក្នុងប្រទេសក្រីក្រទាំងនោះអាចជះឥទ្ធិពលអវិជ្ជមានដល់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ ការអភិវឌ្ឍទាំងនោះអាចមិនមានតុល្យភាពដោយសារតែតម្លៃកម្លាំងពលកម្មទាបនិងពន្ធដែលកំណត់តិច ដែលធ្វើឱ្យប្រព័ន្ធទីផ្សារទាំងមូលនៅក្នុងសេដ្ឋកិច្ចនៃប្រទេសក្រីក្រទាំងនោះត្រូវបានបំផ្លាញ (Hite, 2000)។ ធនធានរបស់ប្រទេសក្រីក្របាត់បង់ច្រើនជាងពួកគេទទួលបានអត្ថប្រយោជន៍ពីពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគបរទេស។ សំខាន់ជាងនេះទៅទៀត រចនាសម្ព័នសេដ្ឋកិច្ចប្រទេសទាំងមូលដែលរណប កំណត់និងទទួលឥទ្ធិពលពីប្រទេសសេដ្ឋកិច្ចស្នូល អាចធ្វើឱ្យមានលំហូរធនធានមនុស្សយ៉ាងច្រើនចេញពីប្រទេសក្រីក្រទៅកាន់ប្រទេសអ្នកមានដើម្បីស្វែងរកការងារ។ កង្វះធនធានមនុស្សនេះធ្វើឱ្យប្រទេសក្រីក្រកាន់តែលំបាកនៅក្នុងការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ច។ Matunhu (2011) បន្ថែមថា ក្នុងប្រវត្តិសាស្រ្តនៃការអភិវឌ្ឍប្រទេសកន្លងមក មានវេជ្ជបណ្ឌិត គ្រូពេទ្យ វិស្វករ និង ស្ថាបត្យករជនជាតិអាហ្វ្រិកជាច្រើនបានផ្លាស់ទៅធ្វើការឱ្យប្រទេសអាណានិគមរបស់ខ្លួនពីមុនជាពិសេសនៅអឺរ៉ុប និងអាម៉េរិកខាងជើង ដោយសារពួកគេអាចទទួលបានប្រាក់ខែខ្ពស់។ ដូច្នេះ ការកេងប្រវ័ញ្ចនៃប្រទេសសេដ្ឋកិច្ចស្នូល គឺជាមូលហេតុជាក់ស្តែងបញ្ជាក់ពីការអភិវឌ្ឍតិចតួចរបស់ប្រទេសរណបសេដ្ឋកិច្ច។

### ៥. សន្និដ្ឋាន

សរុបមក វាហាក់បីដូចជាមានគំនិតពីរផ្ទុយគ្នា ចំពោះការអភិវឌ្ឍតិចតួចនៃបណ្តាក្រីក្រនៅក្នុងទស្សនទានទ្រឹស្តីពឹងផ្អែក (Dependency)។ អ្នកទ្រឹស្តីនេះមួយចំនួនបានចង្អុលបង្ហាញថាឥទ្ធិពលនៃប្រព័ន្ធមូលធននិយមពិភពលោកធ្វើឱ្យប្រទេសទន់ខ្សោយមានការការអភិវឌ្ឍតិចតួចមិនដើរទៅមុខ។ ពួកគេ

ត្រូវបានកេងប្រវ័ញ្ចគ្រប់រូបភាពនិងជាប្រព័ន្ធដោយសារការដោះដូរផលិតផលមិនស្មើភាពគ្នានៅក្នុងលក្ខខណ្ឌនៃទីផ្សារអន្តរជាតិកំណត់ដោយប្រទេសមហាអំណាចសេដ្ឋកិច្ច។ ប្រទេសក្រីក្រទទួលបានកម្រៃទាបបំផុតពីផលិតផលកសិកម្មដែលនាំចេញទៅលក់នៅប្រទេសអ្នកមាន ខណៈដែលប្រទេសសេដ្ឋកិច្ចស្ទួលទទួលបានអត្ថប្រយោជន៍យ៉ាងច្រើនពីការនាំចេញទំនិញនិងផលិតផលឧស្សាហកម្ម។ ជាងនេះទៅទៀត វត្ថុធាតុដើមដូចជា រ៉ែ មាស និង បុកស៊ីតជាដើម ត្រូវបានរុករក ជីក និងដឹកជញ្ជូនទៅកាន់ប្រទេសមូលធននិយម តាមរយៈការដោះដូរពានិជ្ជកម្មនេះ (Isbister, 1991)។ លើសពីនេះទៅទៀត ការអភិវឌ្ឍតិចតួចរបស់ប្រទេសតតិយលោក អាចលើកឡើងតាមរយៈការជ្រៀតចូលនៃក្រុមហ៊ុនសាជីវកម្មពហុជាតិបរទេសនៅក្នុងប្រទេសក្រីក្រទាំងនោះ។ ក្រុមហ៊ុនទាំងនោះទទួលបានអតិរេកសេដ្ឋកិច្ចយ៉ាងច្រើនពីប្រទេសក្រីក្រ ហើយបញ្ជូនទៅប្រទេសកំណើតរបស់ពួកគេយ៉ាងច្រើន ដូចដែលបានលើកឡើងខាងលើ។ ពួកគេនាំយកមកនូវដើមទុនតិចតួច ប៉ុន្តែខ្ចីពីអ្នកសន្សំក្នុងស្រុក និងធនាគារដើម្បីរកផលចំណេញ។ ដូចគ្នាផងដែរ ពួកគេបង្កើតលំនាំឧស្សាហកម្មដើម្បីបម្រើផលប្រយោជន៍ឱ្យប្រទេសសេដ្ឋកិច្ចស្ទួលរបស់ពួកគេ ដែលធ្វើឱ្យប្រទេសរណបសេដ្ឋកិច្ចទាំងនោះមិនអាចប្រកួតប្រជែងដោយស្មើភាពក្នុងពាណិជ្ជកម្ម និងទីផ្សារអន្តរជាតិបាន។ ចំណុចមួយទៀតគឺថា រចនាសម្ព័ន្ធសេដ្ឋកិច្ចនៃប្រទេសក្រីក្រត្រូវបានខូចទ្រង់ទ្រាយ ដែលកំណត់ដោយអំណាចនយោបាយរបស់ប្រទេសសេដ្ឋកិច្ចស្ទួល។ ប្រការនេះធ្វើឱ្យប្រទេសក្រីក្រកាន់តែលំបាកក្នុងការវិវត្តន៍ទៅមុខនិងរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍជាតិ។

ទោះជាយ៉ាងណាក៏ដោយ អ្នករិះគន់ទ្រឹស្តី(Dependency Critics) នេះមួយចំនួនបានអះអាងផ្ទុយគ្នាថា ភាពក្រីក្រនៅក្នុងប្រទេសតតិយលោកគឺបណ្តាលមកពីភាពទន់ខ្សោយ និង កត្តាខាងក្នុងជាជាងការភ្ជាប់ហេតុផលទៅខាងក្រៅជាពិសេសប្រព័ន្ធមូលធននិយមពិភពលោក។ ទំនាក់ទំនងដ៏រឹងមាំនៅក្នុងលក្ខខណ្ឌនៃទំនាក់ទំនងពាណិជ្ជកម្ម ការជ្រៀតចូលនៃក្រុមហ៊ុនសាជីវកម្មពហុជាតិ និងស្ថានភាពជាក់ស្តែងនៃប្រព័ន្ធសេដ្ឋកិច្ចសាកលបានផ្តល់ឱ្យប្រទេសក្រីក្រនូវអត្ថប្រយោជន៍ជាច្រើនទៅវិញទេ។ ផ្ទុយទៅវិញរដ្ឋាភិបាលពុករលួយ និងអសមត្ថភាព កង្វះបច្ចេកវិទ្យា និងរចនាសម្ព័ន្ធសង្គមគ្មានផលិតភាពទេ គឺជាមូលហេតុនៃភាពក្រីក្រក្នុងប្រទេស។ ទោះយ៉ាងណា អ្នកគាំទ្រទ្រឹស្តីនេះនៅតែប្រកែកនិងអះអាងដដែលថា ភាពក្រីក្របន្តកើតមានក្នុងបណ្តាប្រទេសតតិយលោកដោយសារភ្ជាប់ហេតុផលនៃការកេងប្រវ័ញ្ចគ្រប់រូបភាព និង ជាប្រព័ន្ធពីសំណាក់ប្រទេសសេដ្ឋកិច្ចស្ទួល (Fenyo, 2000; Long,

1977)។ ពួកគេមិនត្រឹមតែកេងប្រវ័ញ្ចធនធានធម្មជាតិនោះទេ ប៉ុន្តែព្រមទាំងធនធានមនុស្សទៀតផង។ ឧទាហរណ៍ ប្រទេសមួយចំនួននៅអាម៉េរិកឡាទីនធ្លាប់មានភាពរឹងមាំខាងសេដ្ឋកិច្ចក្នុងប្រវត្តិសាស្ត្រ ប៉ុន្តែចុងក្រោយមានការអភិវឌ្ឍតិចតួចបន្ទាប់ពីមានការជ្រៀតជ្រែក និងកេងប្រវ័ញ្ចពីប្រព័ន្ធសេដ្ឋកិច្ចមូលធន ជាពិសេសក្រោយសង្គ្រាមលោកលើកទីពីរ (Ray, 1973; Valenzuela & Valenzuela, 1978)។

តាមទស្សនៈខ្ញុំផ្ទាល់ ការអភិវឌ្ឍតិចតួចនិងយឺតយ៉ាវនៃបណ្តាប្រទេសក្រីក្រក្នុងពិភពលោក គឺបណ្តាលមកពីការកេងប្រវ័ញ្ចនៃប្រទេសសេដ្ឋកិច្ចស្នូល និង ភាពអសកម្មខាងក្នុងរបស់ប្រទេសទាំងនោះផងដែរ ដូចជា អំពើពុករលួយ អសមត្ថភាព កង្វះខាតបច្ចេកវិទ្យា និងរចនាសម្ព័ន្ធសង្គមខ្សោយដូចដែលបានលើកឡើងនិងពន្យល់ខាងដើម ។

# ឯកសារយោង/គន្ថនិទ្ទេស


Bodenheimer, S. (1971). Dependency and imperialism: The roots of Latin American underdevelopment. *Politics & Society, 1*(3), 327-357.

Cardoso, F. H., & Faletto, E. (1979). *Dependency and Development in Latin America (Dependencia Y Desarrollo en América Latina, Engl.)*: Univ of California Press.

Chukwuemeka, E., Anazodo, R., & Nzewi, H. N. P. (2011). African Underdevelopment and the Multinationals - A Political Commentary. *Journal of Sustainable Development, 4*(4), 101-109.

Desai, V., & Potter, R. B. (2002). *The companion to development studies*.

Fenyo, M. D. (2000). Persistent Underdevelopment: Change and Economic Moderization in the West Indies. *Journal of Third World Studies, 17*(1), 270-272.

Grosfoguel, R. (2000). Developmentalism, Modernity, and Dependency Theory in Latin America.

Hite, A. (2000). From Modernization to Globalization: Perspectives on Development and Social Change (Blackwell Readers in Sociology).

Isbister, J. (1991). *Promises not kept: The betrayal of social change in the Third World*: Kumarian Press Inc.

Long, N. (1977). *An introduction to the sociology of rural development*: Tavistock London.

Matunhu, J. (2011). A critique of modernization and dependency theories in Africa: Critical assessment. *African Journal of History and Culture, 3*(5), 65-72.

Preston, P. (2011). *Theories of development* (Vol. 107): Routledge.

Preston, P. W. (1996). *Development theory: An introduction*: Blackwell Oxford.

Ray, D. (1973). The dependency model of Latin American underdevelopment: Three basic fallacies. *Journal of Interamerican Studies and World Affairs, 15*(1), 4-20.

Santos, T. d. (1970). The structure of dependence. *The American Economic Review, 60*(2), 231-236.

Saul, J. S. (2006). *Development after globalization: Theory and practice for the embattled South in a new imperial age*: Cambridge Univ Press.

So, A. Y. (1990). *Social change and development: Modernization, dependency and world-system theories* (Vol. 178): SAGE Publications, Incorporated.

STEIN, L. (1979). Dependency theories and underdevelopment. *Journal of Economic Studies, 6*(1), 64-85.

Valenzuela, J. S., & Valenzuela, A. (1978). Modernization and dependency: Alternative perspectives in the study of Latin American underdevelopment. *Comparative politics*, *10*(4), 535-557.

Webster, A. (1984). *Introduction to the Sociology of Development* (Vol. 84): Macmillan London.

Willis, K. (2011). *Theories and practices of development*: Taylor & Francis.